**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ..០៣៣./...ន. គ. ស/ /២៦

# សេចក្តីជូនដំណឹង

## ស្តីពី

## ការដាក់ឱ្យអនុវត្តប្រកាសស្តីពីកាតព្វកិច្ចដាក់តម្កល់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ

**និយ័តករគណនេយ្យនិងសវនកម្ម(ន.គ.ស.)** មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ម្ចាស់សហគ្រាស ប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ ភាគីពាក់ព័ន្ធ និងសាធារណជនទាំងអស់ឱ្យបានជ្រាបថា អនុវត្តតាមការសម្រេចដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** នៅក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៩ **អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ(អ.ស.ហ.)**បានដាក់ឱ្យអនុវត្តនូវប្រកាសលេខ០៦៣ អ.ស.ហ.ប្រក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៦ ស្តីពីកាតព្វកិច្ចដាក់តម្កល់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ ជំនួសប្រកាសលេខ៥៦៣ សហវ.ប្រក ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០ ស្តីពីកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ។ ការដាក់ចេញប្រកាសថ្មីឱ្យអនុវត្តជំនួសប្រកាសចាស់ខាងលើ គឺជាក្របខណ្ឌអនុលោមភាពថ្មីនៃការដាក់តម្កល់របាយការណ៍ហិរញ្ញវត្ថុ និងការដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យក្នុងគោលបំណងលើកកម្ពស់ និងពង្រឹងអនុលោមភាពតាមបទប្បញ្ញត្តិគណនេយ្យនិងសវនកម្ម ព្រមទាំងផ្តល់ភាពបត់បែននិងទន់ភ្លន់ដល់បុគ្គលជាប់កាតព្វកិច្ច។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមម្ចាស់សហគ្រាស ប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ ភាគីពាក់ព័ន្ធ និងសាធារណជនទាំងអស់ជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ១៣ កើត ខែ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា គ.ស.២០២៦

**និយ័តករគណនេយ្យនិងសវនកម្ម**

សូមទាញយកប្រកាសនេះ

តាមរយៈ QR Code ខាងក្រោម

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
ទូរស័ព្ទ ០២៣ ៨៨២ ១១១
Phone: 023 882 111
អ៊ីម៉ែល : info@acar.gov.kh